ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
លេខ ១១៣ "ឃ១"
ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២២
សំណុំរឿងព្រហ្មទណ្ឌលេខ ៤១០៩
ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ ៣៦៣៧
ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនាថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២ វេលាម៉ោង០២និង៣០ នាទីរសៀល នាសាលសវនាការទី០៩ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៤១០៩ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] **សាន់នី** ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅសង្កាត់ [redacted] ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅ ផ្ទះលេ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សារឿង (រស់) ម្តាយឈ្មោះ [redacted] សួរ (រស់) ប្តីឈ្មោះ [redacted] សុភណា (រស់) មានកូន ០១នាក់ ទោសពីមុន "គ្មាន" ជានីតិជន (ក្រៅឃុំ) ។

-ជាប់ចោទពីបទ: **ផលិត រក្សាទុក និងចែកចាយថ្នាំលាបស្បែក** (**ឡេលាយ**) ប្រព្រឹត្តនៅចំណុចផ្ទះលេខអឺ១៨ ផ្លូវលេខ១០ សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា**១៧** ,មាត្រា**៦៣** នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវាកម្ម និងមាត្រា**១០** នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ នៃក្រសួងមហាផ្ទៃ បានចុះបង្ក្រាបករណី ផលិត រក្សាទុក និងចែកចាយថ្នាំលាបស្បែក (ឡេលាយ) ដែលមានទីតាំងផ្ទះលេខអឺ១៨ ផ្លូវលេខ ១០ សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដែលទីតាំងខាងលើបាន ផលិត រក្សាទុក និងចែកចាយថ្នាំ



Scanned with CamScanner

លាបស្បែក (ឡេលាយ) គ្មានអាជ្ញាប័ណ្ណពីក្រសួងសុខាភិបាល ដែលមានម្ចាស់ឈ្មោះ [redacted] សាន់នី ភេទស្រី អាយុ៣៧ឆ្នាំ ពិតប្រាកដមែន ។

-បានឃើញ របាយការណ៍សំយោគលេខ ០២៤ /២០២១ រ.ប.ក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ នៃក្រសួងមហាផ្ទៃ ។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ១០១ អ.យ.ជ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ឯកសារភស្តុតាងនានានៅក្នុងសំណុំរឿង ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សាន់នី បានឆ្លើយសារភាពថា៖ ខ្លួនបានបើកអាជីវកម្មលក់ឡេនេះ អស់រយៈពេលជាងមួយឆ្នាំមកហើយ ប៉ុន្តែអាជីវកម្មនេះមិនមែនជាលក្ខណៈទ្រង់ទ្រាយធំនោះទេ។ នៅពេលដែរមានអតិថិជនទាក់ទងទិញឡេ ទើបខ្លួនបានទៅទិញឡេ ពីផ្សារអូឡាំពិក និងទំនាក់ទំនងទិញតាមរយៈ (អនឡាញ) យកមកច្រក់ដាក់កំប៉ុងដែលមានដាក់ឈ្មោះផលិតផល ផយ ស្គីនឃែរ ដែលជាឈ្មោះ អាជីវកម្មរបស់ខ្លួន តែចំនួនដែលខ្លួនបានលក់នោះ ត្រឹមចំនួន១០ ទៅ២០ កំប៉ុងតែប៉ុណ្ណោះ ស្របពេលស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩ អាជីវកម្មរបស់ខ្លួនមិនសូវដំណើការនោះទេ។ ចំពោះផលិតផលឡេខាងលើ មិនបានឆ្លងកាត់ការត្រួតពិនិត្យបច្ចេកទេសនោះទេ ដោយខ្លួនយកឡេខាងលើយកមកលាបសាក់លើរូបខ្លួន ដោយឃើញថាមានប្រសិទ្ធភាព (ស្បែកសរលោង) ក៏បានយកមកលក់បន្តតែម្តង។ ក្រៅពីឡេនេះខ្លួនមិនបានលក់ផលិតផលផ្សេងទៀតនោះទេ ក្រោយពេលដែលសមត្ថកិច្ចចុះហាមឃាត់ និងបិទទីតាំងខាងលើនោះ ខ្លួនមិនបានលក់ ឬបើកអាជីវកម្មទៀតនោះទេ។ ខ្លួនទទួលស្គាល់ថាពិតជាបានលក់ផលិតផលឡេ ដោយគ្មានច្បាប់អនុញ្ញាតពីក្រសួងសុខា-ភិបាល ពិតប្រាកដមែន។ ខ្លួនសំណូមពរ ឱ្យតុលាការមេត្តាផ្តល់ស្ថានសម្រាល និងព្យួរទោសដល់រូបខ្លួនផង ព្រោះខ្លួនបានដឹងពីទោសកំហុសដែលបានប្រព្រឹត្តនេះហើយ និងសូមសន្យាថាឈប់លក់ផលិតផលដែលគ្មានច្បាប់ អនុញ្ញាតតទៅទៀតហើយ។

-តាមអំណានកំណត់ហេតុឃាត់វត្ថុតាងបណ្តោះអាសន្ន៖ ១.សាប៊ូដុសខ្លួន AKARA ចំនួន៩កេស ២.ម្សៅទឹកផ្លែឈើ Jasmine DC ចំនួន៨កេស ក្នុង១កេសមាន៥០ប្រអប់ ៣.ម៉ាសបិទមុខប្រភេទទឹកចម្រុះ Sleep Mask ចំនួន១០កេស ក្នុង១កេសមាន២០កញ្ចប់ ៤.សាប៊ូដុំដុសខ្លួន Vitamin Scrub Soap ចំនួន១១០ដុំ ៥.សាប៊ូដុំដុសខ្លួន អត់ម៉ាក ចំនួន ២កេស ៦.សាប៊ូទឹកដុសខ្លួន ចំនួន៣៥ដប ៧.ថ្នាំលាបស្បែក(ឡេលាយ) ម៉ាក ONITA Night Cream និង Day Cream ចំនួន៧០ខ្លង ៨.Phoy Face Serum ចំនួន១២ដប ៩.Serum Phoy Skin Care ចំណុះ២00ml ចំនួន១០ដប ១០.ថ្នាំលាបស្បែក(ឡេលាយ) ម៉ាក Dariya(VIP) ចំនួន១កេស ក្នុង១កេសមាន៩០ប្រអប់ ១១.ថ្នាំលាបស្បែកចម្រុះ (ឡេលាយ) ចំនួន៧កេស ក្នុង១កេសមាន៤ផង់ធំ ១២.ខ្លងសម្រាប់វិចខ្ចប់ ចំនួន២កេស ១៣. ថ្នាំលាបស្បែក (ឡេលាយ) ប្រអប់ពណ៌ស ចំនួន១កេសធំ ក្នុង១កេសមាន៣២០ខ្លង ១៤.ថ្នាំលាបស្បែក (ឡេលាយ) កូនកាត់សខ្លាំង ចំនួន១០០កំប៉ុង ១៥.ថ្នាំលាបស្បែក(ឡេលាយ)ចម្រុះ ចំនួន១១២ខ្លង ។

## សេចក្តីសន្និដ្ឋានម្តងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សាន់នី ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ នៅក្នុងអង្គសវនាការនេះឃើញថា កាលពីអឡុងឆ្នាំ២០១៩ ជនជាប់ចោទពិតជាបានប្រព្រឹត្ត អំពើ ផលិត រក្សាទុក និងចែកចាយថ្នាំលាបស្បែក (ឡេលាយ) ពិតប្រាកដមែន តាមចម្លើយជនជាប់ចោទ បានឆ្លើយសារ

ភាពរបស់ជនជាប់ចោទនេះ តំណាងអយ្យការយល់ឃើញថាជនជាប់ចោទនេះ ពិតជាបានប្រព្រឹត្តអំពើ ដូចការចោទប្រកាន់ប្រាកដមែន ដូច្នេះតំណាងអយ្យការស្នើសុំតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ១០១ អ.យ.ជ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ទុកជាបានការដដែល និងប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សាន់នី បានធ្វើសេចក្តីសន្និដ្ឋានការពារថា ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ ,ក្រោយពីស្តាប់ការសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ឃើញថាកូនក្តីរបស់ខ្លួន បានឆ្លើយសារភាពថា ខ្លួនពិតជាបានទិញឡេពីផ្សារ និងតាមរយៈអនឡាញ យកមកដាក់ឈ្មោះម៉ាកផលិតផល ដើម្បីយកមកលក់បន្តពិប្រាកដមែន។ ដោយសារតែកូនក្តីខ្លួនដឹងពីទោសកំហុស និងសន្យាកសាងខ្លួនឈប់ លក់ផលិតផលដែលគ្មានច្បាប់អនុញ្ញាតទៀតហើយ ព្រោះកូនក្តីខ្លួនមានការយល់ដឹងតិចពីបញ្ហាផ្លូវច្បាប់ ហើយមិនដឹងថា ការទិញឡេយកមកលក់បន្តបែបនេះ ហើយបិទឈ្មោះលើកំប៉ុងឡេខុសច្បាប់នោះទេ ម្យ៉ាងវិញទៀតកូនក្តីរបស់ខ្លួនបាន ពិចារណាពីទោសកំហុសដែលខ្លួនបានប្រព្រឹត្តនេះហើយ។ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទស្នើសុំអោយ តុលាការមេត្តាជួយព្យួរទោសដល់កូនក្តីរបស់ខ្លួនដោយក្តីអនុគ្រោះផង។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] សាន់នី បាននិយាយសំដីចុងក្រោយបង្អស់ថា បានសុំឱ្យតុលាការជួយបន្ធូរ-បន្ថយទោស និងមេត្តាជួយព្យួរទោសដល់រូបខ្លួនផង ព្រោះខ្លួនដឹងពីទោសកំហុសដែលបានប្រព្រឹត្តនេះហើយ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានកំណត់ហេតុទទួលវត្ថុចាប់យក
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា
- ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ៤១០៩ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ មកជំនុំជម្រះតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ១០១ អ.យ.ជ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] **សាន់នី** ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ ពីបទ **ផលិត រក្សាទុក និងចែកចាយថ្នាំលាបស្បែក** ( **ឡេលាយ** ) ប្រព្រឹត្តនៅចំណុចផ្ទះលេខ អ៊ី១៨ ផ្លូវលេខ១០ សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា**១៧** ,មាត្រា**៦៣** នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាពលើផលិតផលទំនិញ និងសេវាកម្ម និងមាត្រា**១០** នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ។

**-និយមន័យមាត្រា១៧៖** ត្រូវបានហាមឃាត់ជាដាច់ខាតការក្លែងផលិតផលទំនិញដែលជាកម្មវត្ថុធ្វើ ពាណិជ្ជកម្ម ឬទុកសំរាប់ធ្វើពាណិជ្ជកម្ម ដោយធ្វើការកែច្នៃផលិតផលទំនិញតាមរបៀបណាមួយ ដោយធ្វើការបញ្ចូលបន្ថែម ការដកចេញ



Scanned with CamScanner

ឬការប្តូរជំនួសនៃភាគណាមួយ ឬភាគទាំងមូលដែលពុំត្រូវអនុញ្ញាតអោយទេដោយបទប្បញ្ញត្តិ ឬដោយទំលាប់ ពុំមានបទប្បញ្ញត្តិ ឬដែលមិនសមស្របទៅនឹងបទប្បញ្ញត្តិ។ ការធ្វើពាណិជ្ជកម្មនៃផលិតផលទំនិញណាមួយដោយដឹងថា ផលិតផលទំនិញនោះជាផលិតផលទំនិញក្លែងក្លាយ ត្រូវហាមឃាត់ជាដាច់ខាត។

**-និយមន័យមាត្រា៦៣៖** ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា១៦ មាត្រា១៧ មាត្រា១៨ ឬ មាត្រា២១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ)ខែ ដល់ ១ (មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល ឬទោសណាមួយនៃទោសទាំងពីរនេះ ។

**-និយមន័យមាត្រា១០៖** ១-ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ រៀល (មួយលានរៀល) ដល់ ៥.០០០.០០០ រៀល (ប្រាំលានរៀល) ចំពោះជនណាដែលបាន -ផ្សព្វផ្សាយផលិតផលឱសថ និងគ្រឿងសំអាងតាមវិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី សារព័ត៌មាន ខិតប័ណ្ណ សិក្ខាសាលា ឬ តាមមធ្យោបាយផ្សេងៗទៀត ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល -ប្រព្រឹត្តល្មើសនឹងបែបបទ និងល័ក្ខខ័ណ្ឌក្នុងការគ្រប់គ្រងថែរក្សាផលិតផលឱសថ -បើកបិទ ឬ ប្តូរទីតាំងឱសថស្ថាន ឱសថស្ថានរង និងគ្រឹះស្ថានលក់គ្រឿងសំអាង ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល។ ១-ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ រៀល (ប្រាំលានរៀល) ដល់ ១០.០០០.០០០ រៀល (ដប់លានរៀល) ចំពោះជនណាដែលបាន -បើក បិទ ឬ ប្តូរទីតាំងគ្រឹះស្ថានលក់ដុំឱសថ គ្រឹះស្ថាននាំចូល ចែកចាយឱសថគ្រឹះស្ថាននាំចូល នាំចេញឱសថ ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល -ប្រព្រឹត្តល្មើសនឹងបែបបទ និងល័ក្ខខ័ណ្ឌពាណិជ្ជកម្ម អាហារ័ណ នីហរ័ណឱសថ -នាំចូល ឬ នាំចេញ ផលិតផលឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល -ចែកចាយ តាំងលក់ ឬ លក់ផលិតផលឱសថ និងគ្រឿងសំអាងដែលគ្មាន ចុះលេខទិដ្ឋាការ ឬ បញ្ជីកាពីក្រសួងសុខាភិបាល -លក់ឱសថខូចគុណភាព និងឱសថផុតកំណត់ប្រើប្រាស់ ។ ៣-ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ រៀល (ដប់លានរៀល) ដល់ ២០.០០០.០០០ រៀល (ម្ភៃលានរៀល) ចំពោះជនណាដែលបាន -បើក បិទ ឬ ប្តូរទីតាំងគ្រឹះស្ថានផលិតឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល -ប្រព្រឹត្តល្មើសនឹងបែបបទ និងល័ក្ខខ័ណ្ឌបច្ចេកទេសផលិតឱសថនាំចូលវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច សម្ភារៈវេចខ្ចប់ម៉ាស៊ីន ឧបករណ៍សម្រាប់ផលិតឱសថ ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល -ផលិតឱសថដែលមានគុណភាព មិនត្រឹមត្រូវតាមស្តង់ដារគុណភាពក្នុង ឯកសារសុំទិដ្ឋាការឱសថ -ស្តុកវត្ថុធាតុដើម សម្ភារៈវេចខ្ចប់ ម៉ាស៊ីនឧបករណ៍ផលិត ផលិតផលឱសថ ក្រៅពីគ្រឹះស្ថានអាជីវកម្ម ផលិតកម្ម ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។ ៤-ករណីបទល្មើសខាងលើ បានបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ឬ អាយុជីវិតមនុស្ស ក្រសួងសុខាភិបាលត្រូវចេញប្រកាសផ្អាកសកម្មភាពផលិត អាហរ័ណ នីហរ័ណ និងពាណិជ្ជកម្មឱសថជាបន្ទាន់ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់។ ៥-ទោសទណ្ឌទាំងឡាយណាដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០រៀល (មួយលានរៀល) ដល់ ១០.០០០.០០០ រៀល (ដប់លានរៀល) ក្រសួងសុខាភិបាលមាន សិទ្ធិពិន័យអន្តរការណ៍។ ក្នុងករណីរឹងរូសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្រសួងសុខាភិបាលត្រូវកសាង សំណុំរឿងបញ្ជូនទៅតុលាការ ។

២-តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ១០១ អ.យ.ជ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជាក់ថា កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ នៅចំណុចផ្ទះលេខ អឺ១៨ ផ្លូវលេខ១០ សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ពិតជាបានធ្វើសកម្មភាព លក់ឡេដោយគ្មានច្បាប់អនុញ្ញាត អំពើនេះប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted]សាន់នី ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ ពិតប្រាកដមែន ។



Scanned with CamScanner

៣-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សាន់នី បានឆ្លើយសារភាពនាពេលសវនាការថា៖ ខ្លួនបានបើកអាជីវកម្មលក់ឡេនេះអស់រយៈពេលជាងមួយឆ្នាំមកហើយ ប៉ុន្តែអាជីវកម្មនេះមិនមែនជាលក្ខណៈទ្រង់ទ្រាយធំនោះទេ។ នៅពេលដែរមានអតិថិជនទាក់ទងទិញឡេ ទើបខ្លួនបានទៅទិញឡេ ពីផ្សារអូឡាំពិក និងទំនាក់ទំនងទិញតាមរយៈ (អនឡាញ) យកមកច្រក់ដាក់កំប៉ុងដែលមានដាក់ ឈ្មោះផលិតផល ផយ ស្គីនឃែរ ដែលជាឈ្មោះ អាវីកម្ម របស់ខ្លួន តែចំនួនដែលខ្លួនបានលក់នោះ ត្រឹមចំនួន១០ ទៅ២០ កំប៉ុងតែប៉ុណ្ណោះ ស្របពេលស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩ អាជីវកម្មរបស់ខ្លួនមិនសូវដំណើការនោះទេ។ ចំពោះផលិតផលឡេខាងលើ មិនបានឆ្លងកាត់ការត្រួតពិនិត្យបច្ចេកទេសនោះទេ ដោយខ្លួនយកឡេខាងលើយកមកលាបសាក់លើរូបខ្លួន ដោយឃើញថាមានប្រសិទ្ធភាព (ស្បែកសរលោង) ក៏បានយកមកលក់បន្តតែម្តង។ ក្រៅពីឡេនេះខ្លួនមិនបាន លក់ផលិតផលផ្សេងទៀតនោះទេ ក្រោយពេលដែលសមត្ថកិច្ចចុះហាមឃាត់ និងបិទទីតាំងខាងលើនោះ ខ្លួនមិនបានលក់ ឬបើកអាជីវកម្មទៀតនោះទេ។ ខ្លួនទទួលស្គាល់ថាពិតជាបានលក់ផលិតផលឡេដោយគ្មានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល ពិតប្រាកដមែន។ ខ្លួនសំណូមពរ ឱ្យតុលាការមេត្តាផ្តល់ស្ថានសម្រាល និងព្យួរទោសដល់រូបខ្លួនផង ព្រោះខ្លួនបានដឹងពីទោសកំហុសដែលបានប្រព្រឹត្តនេះហើយ និងសូមសន្យាថាឈប់លក់ផលិតផលដែលគ្មានច្បាប់អនុញ្ញាតតទៅទៀតហើយ។

៤-ឆ្លងតាមការស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ ការពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿងឃើញថាមានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុ អាចបញ្ជាក់ឱ្យឃើញថាជនជាប់ចោទ ពិតជាបាន ទិញឡេលាយ យកមកលក់បន្តដោយគ្មានច្បាប់អនុញ្ញាត ប្រាកដមែន។ ជនជាប់ចោទនេះ បានឆ្លើយសារភាពដឹងពីទោសកំហុសដែល ខ្លួនបានប្រព្រឹត្តម្យ៉ាងវិញទៀត ជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសជាលើកទីមួយ គប្បីតុលាការ ពិចារណាអំពីការព្យួរ ទោសលើជនជាប់ចោទ ដោយអនុលោមទៅតាមបញ្ញត្តិមាត្រា១០៦ និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ ។

៥-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សាន់នី ដែលបានប្រព្រឹត្តបទល្មើស ផលិត រក្សាទុក និងចែកចាយថ្នាំលាបស្បែក (ឡេលាយ) នោះ តុលាការពិចារណា ឃើញថាជនជាប់ចោទខាងលើនេះ ពិតជាចារីដែលបានប្រព្រឹត្តអំពើល្មើសនេះដោយផ្ទាល់ប្រាកដមែន ហើយអំពើនេះ បានបំពានទៅនឹងនីត្យានុកូលភាពនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចែងក្នុងបញ្ញត្តិមាត្រា១៧ ,មាត្រា៦៣ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាពលើផលិត ផលទំនិញ និងសេវាកម្ម និងមាត្រា១០ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ។

៦-អំពើល្មើស និងសកម្មភាពរបស់ជនជាប់ចោទ បានធ្វើឱ្យខូចសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈជាពិសេស ប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋទូទៅ ដែលច្បាប់បានការពារ និងតម្រូវឱ្យផ្តន្ទាទោស ។

៧-ពេលធ្វើសកម្មភាពប្រព្រឹត្តបទល្មើស ជនជាប់ចោទមានសតិបញ្ញាស្មារតីគ្រប់គ្រាន់ ប្រព្រឹត្តអំពើល្មើសច្បាប់រហូតសម្រេចតាមបំណងរបស់ខ្លួន ហើយជនជាប់ចោទជានីតិជនដែលមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។

៨-វត្ថុចាប់យកដែលត្រូវរឹបអូសរួមមាន៖ ១.សាប៊ូដុសខ្លួន AKARA ចំនួន៩កេស ២.ម្សៅទឹកផ្លែឈើ Jasmine DC ចំនួន៨កេស ក្នុង១កេសមាន៥០ប្រអប់ ៣.ម៉ាសបិទមុខប្រភេទទឹកចម្រុះ Sleep Mask ចំនួន១០កេស ក្នុង១កេសមាន ២០កញ្ចប់ ៤.សាប៊ូដុំដុសខ្លួន Vitamin Scrub Soap ចំនួន១១០ដុំ ៥.សាប៊ូដុំដុសខ្លួន អត់ម៉ាក ចំនួន២កេស ៦.សាប៊ូទឹកដុសខ្លួន ចំនួន៣៥ដប ៧.ថ្នាំលាបស្បែក(ឡេលាយ) ម៉ាក ONITA Night Cream និង Day Cream ចំនួន៧០ខ្លង ៨.Phoy Face Serum ចំនួន១២ដប ៩.Serum Phoy Skin Care ចំណុះ២០០ml ចំនួន១០ដប ១០.ថ្នាំលាបស្បែក(ឡេលាយ) ម៉ាក Dariya(VIP) ចំនួន១កេស ក្នុង១កេសមាន៩០ប្រអប់ ១១.ថ្នាំលាបស្បែកចម្រុះ (ឡេលាយ) ចំនួន៧កេស ក្នុង១កេស



Scanned with CamScanner

មាន៥ថង់ធំ ១២.ខ្លងសម្រាប់វិចខ្ចប់ ចំនួន២កេស ១៣. ថ្នាំលាបស្បែក (ឡេលាយ) ប្រអប់ពណ៌ស ចំនួន១កេសធំ ក្នុង១កេសមាន៣២០ខ្លង ១៤.ថ្នាំលាបស្បែក (ឡេលាយ) កូនកាត់សខ្លាំង ចំនួន១០០កំប៉ុង ១៥.ថ្នាំលាបស្បែក (ឡេលាយ)ចម្រុះ ចំនួន១១២ខ្លង។ វត្ថុតាងទាំងនេះ មានទំនាក់ទំនងនិងបណ្តាលឱ្យមានសកម្មភាពប្រព្រឹត្តបទល្មើសកើតមានឡើង ហេតុនេះគប្បីតុលាការសម្រេចរឹបអូស។

៩-តំណាងអយ្យការប្តឹងសុំតម្កល់ការចោទប្រកាន់ តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ១០១ អ.យ.ជ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល និង សុំតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។ ចំណុចនេះគប្បីតុលាការពិចារណា និងសម្រេចតាមការប្តឹងសុំ ។

១០-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សាន់នី បានធ្វើសេចក្តីសន្និដ្ឋានការពារថា ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ ,ក្រោយពីស្តាប់ការសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ឃើញថាកូនក្តីរបស់ខ្លួន បានឆ្លើយសារភាពថា ខ្លួនពិតជាបានទិញឡេពីផ្សារ និងតាមរយៈអនឡាញ យកមកដាក់ឈ្មោះម៉ាកផលិតផល ដើម្បីយកមកលក់បន្តពិប្រាកដមែន។ ដោយសារតែកូនក្តីខ្លួនដឹងពីទោសកំហុស និងសន្យាកសាងខ្លួនឈប់ លក់ផលិតផលដែលគ្មានច្បាប់អនុញ្ញាតទៀតហើយ ព្រោះកូនក្តីខ្លួនមានការយល់ដឹងតិចពីបញ្ហាផ្លូវច្បាប់ ហើយមិនដឹងថា ការទិញឡេយកមកលក់បន្តបែបនេះ ហើយបិទឈ្មោះលើកំប៉ុងឡេខុសច្បាប់នោះទេ ម្យ៉ាងវិញទៀតកូនក្តីរបស់ខ្លួនបាន ពិចារណាពីទោសកំហុសដែលខ្លួនបានប្រព្រឹត្តនេះហើយ។ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទស្នើសុំអោយ តុលាការមេត្តាជួយព្យួរទោសដល់កូនក្តីរបស់ខ្លួនដោយក្តីអនុគ្រោះផង។ ចំណុចស្នើសុំនេះ គប្បីតុលាការសម្រេចពីចារណា តាមការស្នើសុំរបស់លោកមេធាវី។

១១-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **សាន់នី** ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ ពីបទ **ផលិត រក្សាទុក និងចែកចាយថ្នាំលាបស្បែក** (**ឡេលាយ**) ប្រព្រឹត្តនៅចំណុចផ្ទះលេខ អី១៨ ផ្លូវលេខ១០ សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា១៧ ,មាត្រា**៦៣** នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាពលើផលិតផលទំនិញ និងសេវាកម្ម និងមាត្រា**១០** នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ។

## <u>ហេតុដូច្នេះសម្រេច</u>

**១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ** [redacted] **សាន់នី** ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន **០៦ខែ** (**ប្រាំមួយខែ**) **តែទោសនេះត្រូវអនុវត្តទោសព្យួរធម្មតា និងពិន័យជាប្រាក់ចំនួន ១.០០០.០០០** (**មួយលាន**)**រៀល** ពីបទ៖ **ផលិត រក្សាទុក និងចែកចាយថ្នាំលាបស្បែក** (**ឡេលាយ**) ប្រព្រឹត្តនៅចំណុច ផ្ទះលេខអី១៨ ផ្លូវលេខ១០ សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា**១៧** ,មាត្រា**៦៣** នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាពលើផលិតផលទំនិញ និងសេវាកម្ម មាត្រា**១០** នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ និងមាត្រា**១០៦** ,មាត្រា**១០៧** នៃក្រមព្រហ្មទណ្ឌ។

**២-វត្ថុចាប់យកដែលត្រូវរឹបអូសរួមមាន៖** ១.សាប៊ូដុសខ្លួន AKARA ចំនួន៩កេស ២.ម្សៅទឹកថ្លៃឈើ Jasmine DC ចំនួន៨កេស ក្នុង១កេសមាន៥០ប្រអប់ ៣.ម៉ាសបិទមុខប្រភេទទឹកចម្រុះ Sleep Mask ចំនួន១០កេស ក្នុង១កេសមាន២០កញ្ចប់ ៤.សាប៊ូដុំដុសខ្លួន Vitamin Scrub Soap ចំនួន១១០ដុំ ៥.សាប៊ូដុំដុសខ្លួន អត់ម៉ាក ចំនួន ២កេស ៦.សាប៊ូ



Scanned with CamScanner

ទឹកដុសខ្លួន ចំនួន៣៥ដប ៧.ថ្នាំលាបស្បែក(ឡេលាយ) ម៉ាក ONITA Night Cream និង Day Cream ចំនួន៧០ខ្លង ៨.Phoy Face Serum ចំនួន១២ដប ៩.Serum Phoy Skin Care ចំណុះ២០០ml ចំនួន១០ដប ១០.ថ្នាំលាបស្បែក (ឡេលាយ) ម៉ាក Dariya(VIP) ចំនួន១កេស ក្នុង១កេសមាន៩០ប្រអប់ ១១.ថ្នាំលាបស្បែកចម្រុះ (ឡេលាយ) ចំនួន ៧កេស ក្នុង១កេសមាន៤ថង់ធំ ១២.ខ្លងសម្រាប់វិចខ្ចប់ ចំនួន២កេស ១៣. ថ្នាំលាបស្បែក (ឡេលាយ) ប្រអប់ពណ៌ស ចំនួន១កេសធំ ក្នុង១កេសមាន៣២០ខ្លង ១៤.ថ្នាំលាបស្បែក (ឡេលាយ) កូនកាត់សខ្លាំង ចំនួន១០០កំប៉ុង ១៥.ថ្នាំលាប ស្បែក (ឡេលាយ)ចម្រុះ ចំនួន១១២ខ្លង ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សាន់នី ,ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

| **ក្រឡាបញ្ជី** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃព្រហស្បតិ៍ ៣រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ,ថ្ងៃទី២០ ខែមករា ឆ្នាំ២០២២

| **បានឃើញ**<br>**ចៅក្រមជំនុំជម្រះ** | **ក្រឡាបញ្ជី** |
|---|---|
| [redacted] | [redacted] |